ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍

- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាការគ្រប់គ្រងនិងការអនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ការចាត់ចែង និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលសរសេរកាត់ថា "**ក្រុមប្រឹក្សាមូលនិធិ ស.អ.**" ប្រកបដោយប្រសិទ្ធភាព ស័ក្ដិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពី៖

- យន្តការអនុវត្តមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការប្រមូលនិងការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- លក្ខខណ្ឌនិងនីតិវិធីនៃការទូទាត់រវាងវិភាគទានមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ
- ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

**មាត្រា៣ ._**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ._**

និយមន័យនៃពាក្យបច្ចេកទេសក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្ត** សំដៅដល់ស្ថាប័នទទួលបន្ទុកផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលទទួលស្គាល់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ចំណូលដុល** សំដៅដល់ប្រាក់ចំណូលទាំងអស់របស់ប្រតិបត្តិករទូរគមនាគមន៍ដែលបានមកពីប្រតិបត្តិការទូរគមនាគមន៍ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ ដោយមិនទាន់កាត់កងចំណាយណាទាំងអស់ លើកលែងតែចំណូលពីការលក់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍។

**មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែលប្រើប្រាស់ដើម្បីទ្រទ្រង់ និងលើកកម្ពស់ដល់ការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តទៅសរសេរកាត់ថា "មូលនិធិ **ស.អ.**"។

## ជំពូកទី២
## ការគ្រប់គ្រងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាលមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា៥ ._**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានសមាសភាពចំនួន ០៧ (ប្រាំពីរ) រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១ រូប | អនុប្រធានទី១ |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ រូប | អនុប្រធានទី២ |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | | សមាជិកអចិន្ត្រៃយ៍ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ | | សមាជិក |

សមាសភាពជាក់ស្តែងរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦ ._**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងចាត់ចែង មូលនិធិ **ស.អ.**
- ពិនិត្យនិងអនុម័តលើផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ
- លើកកម្ពស់និងជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព
- ពិនិត្យនិងអនុម័តលើផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- ពិនិត្យនិងអនុម័តលើផែនការនិងយន្តការប្រើប្រាស់មូលនិធិ **ស.អ.** និងយន្តការអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- ពិនិត្យនិងអនុម័តលើគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- គ្រប់គ្រងសមិទ្ធផលដែលទទួលបានពីគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ជូនរាជរដ្ឋាភិបាល
- ធ្វើជាតំណាងស្របច្បាប់របស់មូលនិធិ **ស.អ.** ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នរដ្ឋ ឬឯកជន ដៃគូជាតិនិងអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត
- ពិនិត្យនិងអនុម័តការផ្តល់ ការបន្ត ការផ្ទេរ ការផ្អាក ឬការបញ្ឈប់គម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- ពិនិត្យនិងអនុម័តលើថវិកា រួមទាំងថវិកាសម្រាប់ចំណាយរដ្ឋបាលប្រចាំឆ្នាំ និង
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មូលនិធិ **ស.អ.**។

**មាត្រា៧ ._**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចមានអ្នកជំនាញការជាតិឬអន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញនិងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស។

**មាត្រា៨ ._**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**)។

## ផ្នែកទី២

## ដំណើរការរបស់ក្រុមប្រឹក្សាភិបាលមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា៩ ._**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញតាមគំនិតផ្តួចផ្តើមរបស់ប្រធាន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ឬតាមការស្នើសុំពីសមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ចំនួន ២/៣ (ពីរភាគបី)។

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវដំណើរការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈ ត្រូវបានជូនដំណឹងជាមុនយ៉ាងតិច ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការដល់គ្រប់សមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចអញ្ជើញភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

**មាត្រា១០ .-**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចដំណើរការប្រជុំបាន លុះត្រាតែមានសមាជិកលើសពី ៥០% (ហាសិបភាគរយ) ចូលរួម។ សមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដែលអវត្តមាន ពុំអាចចាត់តំណាងជំនួសបានឡើយ។

កិច្ចប្រជុំរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធានឬប្រធានស្តីទីរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានទី១នៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវបំពេញតួនាទីជាប្រធានស្តីទី។

សមាជិកអង្គប្រជុំទាំងអស់ដែលចូលរួមប្រជុំ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

**មាត្រា១១ .-**

សេចក្តីសម្រេចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធាននៃអង្គប្រជុំមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវរក្សាទុកនៅលេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដោយមានចុះហត្ថលេខារបស់ប្រធានអង្គប្រជុំ។

កិច្ចប្រជុំ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុ ត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខានៃអង្គប្រជុំ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវរៀបចំនិងផ្ញើសេចក្តីព្រាងកំណត់ហេតុជូនសមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល ១២ (ដប់ពីរ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធាន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ចុះហត្ថ-លេខាលើកំណត់ហេតុដែលទទួលបានការកែតម្រូវ ឬការយល់ព្រមពីសមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ទាំងអស់ដែលមានវត្តមានក្នុងកិច្ចប្រជុំ។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនប្រធាន អនុប្រធាន និងសមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

## ផ្នែកទី៣
## លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា១២ .-**

ត្រូវបង្កើតលេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ជាសេនាធិការ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។ លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវដឹកនាំដោយសមាជិកអចិន្ត្រៃយ៍នៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**មាត្រា១៣ ..**

លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ សិក្សា ស្រាវជ្រាវ និងវិភាគលើស្ថានភាពនៃការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីរៀបចំសមិទ្ធិលទ្ធភាពខាងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុនៃផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ
- រៀបចំផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំផែនការនិងយន្តការអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែងជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំនិងសម្របសម្រួលការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍តាមការណែនាំរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- លើកយោបល់អំពីការបន្ត ការផ្ទេរ ការផ្អាក និងការបញ្ឈប់គម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំសេចក្តីព្រាងថវិកាសម្រាប់អនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- រៀបចំសេចក្តីព្រាងថវិកាប្រចាំឆ្នាំរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- ប្រមូលនិងផ្ទៀងផ្ទាត់ការបង់វិភាគទានរបស់ប្រតិបត្តិករទូរគមនាគមន៍ចូល **មូលនិធិ ស.អ.**
- ពិនិត្យ ផ្ទៀងផ្ទាត់ ទូទាត់ និងផាត់ទាត់ការប្រើប្រាស់មូលនិធិ **ស.អ.**
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាពប្រចាំឆ្នាំស្តីពីការអនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- តាមដានលំហូរធនធាននៃមូលនិធិ **ស.អ.** ដែលបានមកពីប្រភពផ្សេងៗទាំងក្នុងនិងក្រៅប្រទេស
- រៀបចំផែនការចំណូលនិងចំណាយជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច
- រាយការណ៍អំពីវឌ្ឍនភាពនៃការប្រើប្រាស់មូលនិធិ **ស.អ.** និងស្នើសុំ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ចាត់វិធានការនានាចំពោះនីតិបុគ្គលដែលទទួលបានមូលនិធិតែមិនអនុវត្តឬអនុវត្តមិនពេញលេញនូវគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- ផ្សព្វផ្សាយគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- រៀបចំ សម្របសម្រួល និងធ្វើកំណត់ហេតុរាល់កិច្ចប្រជុំពិភាក្សារបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- សម្របសម្រួលការងាររដ្ឋបាលទូទៅនិងគ្រប់គ្រងថែរក្សាមូលនិធិ **ស.អ.**
- គ្រប់គ្រងបុគ្គលិកនិងមន្ត្រីទទួលបន្ទុកសម្របសម្រួលការងាររដ្ឋបាលនិងគ្រប់គ្រង **មូលនិធិ ស.អ.**

- រាយការណ៍និងផ្ដល់អនុសាសន៍ជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** នូវរាល់បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងមូលនិធិ **ស.អ.** និង
- តួនាទីនិងភារកិច្ចផ្សេងទៀតដែល **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ប្រគល់ជូន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា១៤ ..**

បន្ទាប់ពីទទួលបានការអនុញ្ញាតពី **ក្រុមប្រឹក្សាមូលនិធិ ស.អ.** លេខាធិការដ្ឋាននៃ**ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចពិគ្រោះយោបល់ជាមួយប្រតិបត្តិករទូរគមនាគមន៍និងបុគ្គលពាក់ព័ន្ធ មុននឹងដាក់សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ទៅ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

**មាត្រា១៥ ..**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវមានកញ្ចប់ថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួន។ ថវិកានេះត្រូវដកចេញពី **មូលនិធិ ស.អ.** ប្រចាំឆ្នាំ យ៉ាងច្រើនចំនួន ១០% (ដប់ភាគរយ)។

ការផ្ដល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីដែលបម្រើការងារក្នុងលេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវសម្រេចជាគោលការណ៍ដោយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន។

## ជំពូកទី៣
## ការប្រមូលនិងការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា១៦ ..**

ប្រភពធនធាននៃមូលនិធិ **ស.អ.** រួមមាន៖

- ការបង់វិភាគទានរៀងរាល់ឆ្នាំចំនួន ០១% (មួយភាគរយ) នៃចំណូលដុល ដោយប្រតិបត្តិករទូរគមនាគមន៍ ស្របតាមច្បាប់ស្ដីពីទូរគមនាគមន៍
- ធនធានដែលរដ្ឋឬក្រសួង ស្ថាប័ន ផ្ដល់ឱ្យមូលនិធិ **ស.អ.** សម្រាប់គម្រោងរួមគ្នា
- ធនធានដែលបានមកពីដៃគូអភិវឌ្ឍន៍
- ហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងប្រភពផ្សេងទៀតសម្រាប់ចំណាយលើសេវារដ្ឋបាល និងសម្រាប់ការផ្គត់ផ្គង់សម្ភារៈបរិក្ខារនិងការឧបត្ថម្ភផ្សេងៗតាមការចាំបាច់ ក្នុងគោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និង
- ប្រភពផ្សេងទៀត។

ប្រភពធនធាននៃមូលនិធិ **ស.អ.** ត្រូវដាក់ចូលក្នុងគណនីប្រាក់បញ្ញើរបស់មូលនិធិ **ស.អ.** នៅរតនាគារជាតិ លើកលែងតែមានការកំណត់ផ្សេងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវចាប់ផ្ដើមបង់វិភាគទានចូលមូលនិធិ **ស.អ.** ចាប់ពីឆ្នាំ២០១៧ តទៅ។

**មាត្រា១៧.-**

ប្រតិបត្តិករទូរគមនាគមន៍ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួច មក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** យ៉ាងយូរបំផុត ៩០ (កៅសិប) ថ្ងៃ ក្រោយការិយបរិច្ឆេទនីមួយៗ។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានចំនួន ០១% (មួយភាគរយ) នៃចំណូលដុល ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួច។ ចំនួនទឹកប្រាក់បង់វិភាគទាននេះ ត្រូវគណនាដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃឆ្នាំចាស់។ ប្រាក់លម្អៀងនៃការគណនាទឹកប្រាក់បង់វិភាគទាននៃឆ្នាំចាស់និងឆ្នាំដែលត្រូវបង់នឹងត្រូវធ្វើនិយ័តកម្ម បន្ទាប់ពីទទួលបានរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដូចមានចែងក្នុងកថាខណ្ឌទី១។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានផ្ទាល់ទៅក្នុងគណនីមូលនិធិ **ស.អ.** យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលសេចក្តីសម្រេចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** អំពីចំនួនទឹកប្រាក់ដែលត្រូវបង់ចូលមូលនិធិ **ស.អ.**។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង់វិភាគទានមូលនិធិ **ស.អ.** ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សំណល់ក្នុងឆ្នាំចាស់នៃមូលនិធិ **ស.អ.** ត្រូវយោងទៅប្រើប្រាស់ជាមួយមូលនិធិ **ស.អ.** ឆ្នាំបន្ទាប់។

**មាត្រា១៨.-**

ប្រតិបត្តិករទូរគមនាគមន៍អាចស្នើសុំការទូទាត់ជាមុនរវាងវិភាគទានមូលនិធិ **ស.អ.** ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ចំនួន ២០% (ម្ភៃភាគរយ) នៃចំនួនវិភាគទានដែលត្រូវបង់ចូល មូលនិធិ **ស.អ.** ចំពោះគម្រោងជាអាទិ៍៖

- ការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការបង្កើតព្រឹត្តិការណ៍និងកម្មវិធីផ្សេងៗក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការបង្កើតកម្មវិធីប្រកួតប្រជែងអំពីទំនើបកម្មនៃបច្ចេកវិទ្យា និងភាពជាសហគ្រិនផ្តើមលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

ដើម្បីអាចស្នើសុំទូទាត់គម្រោងអនុវត្តដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ប្រតិបត្តិករទូរគមនាគមន៍ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវដាក់ពាក្យស្នើសុំជាមុនទៅ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** យ៉ាងយូរត្រឹមត្រីមាសទីមួយនៃឆ្នាំនីមួយៗ
- ត្រូវភ្ជាប់នូវរបាយការណ៍លម្អិតនៃគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- ត្រូវគោរពតាមផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ
- ត្រូវអនុវត្តកាតព្វកិច្ចទាំងឡាយដូចមានកំណត់ក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះ
- តាមការកំណត់ផ្សេងទៀតដោយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

**មាត្រា១៩.-**

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានសិទ្ធិអនុម័តការទូទាត់រវាងវិភាគទានមូលនិធិ **ស.អ.** ប្រចាំឆ្នាំនិងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទូទាត់រវាងវិភាគទានមូលនិធិ **ស.អ.** ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ត្រូវកំណត់បន្ថែមដោយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

**មាត្រា២០ .-**

វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាសេនាធិការក្នុងការអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍។

**មាត្រា២១ .-**

កម្មវត្ថុនៃការប្រើប្រាស់មូលនិធិ **ស.អ.** មានជាអាទិ៍ ដូចខាងក្រោម៖

- ការកសាងហេដ្ឋារចនាសម្ព័ន្ធ មជ្ឈមណ្ឌលនវានុវត្តន៍ មន្ទីរពិសោធន៍ ឬបន្ទប់ពិសោធន៍បម្រើឱ្យការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការអប់រំនិងការបណ្តុះបណ្តាលលើជំនាញទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការគាំទ្រដល់ការបង្កើតអាជីវកម្មនិងសេវាកម្មថ្មីៗលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតផ្នែកទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការបង្កើតព្រឹត្តិការណ៍និងកម្មវិធីផ្សេងៗក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការបង្កើតកម្មវិធីប្រកួតប្រជែងទំនើបកម្មនៃបច្ចេកវិទ្យានិងភាពជាសហគ្រិនថ្មើមលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ចំណាយរដ្ឋបាល និង
- កម្មវត្ថុផ្សេងទៀតដែលអនុម័តដោយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

**មាត្រា២២ .-**

រាល់ចំណាយចំពោះធនធានមនុស្សនិងសម្ភារៈសម្រាប់ដំណើរការ និងការបំពេញភារកិច្ចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** និងលេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** គឺជាចំណាយរដ្ឋបាល ដែលមានជាអាទិ៍៖

- ប្រាក់សម្រាប់ដំណើរការនិងបំពេញភារកិច្ចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** និងលេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- ប្រាក់ឧបត្ថម្ភសម្រាប់សមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- ប្រាក់ឧបត្ថម្ភសម្រាប់ប្រធាន អនុប្រធាន ទីប្រឹក្សាបច្ចេកទេស មន្ត្រីរាជការ និងបុគ្គលិកនៃលេខាធិការ-ដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- ការទិញ ការជួល ការជួសជុល ឬការថែទាំគ្រឿងសង្ហារឹម សម្ភារៈការិយាល័យ មធ្យោបាយនិងសម្ភារៈរដ្ឋបាល

- ការទិញ ការជួល ការជួសជុល ឬការថែទាំយានជំនិះ
- ចំណាយចំពោះប្រេងឥន្ធនៈ ប្រេងរំអិល និង
- ចំណាយជាក់ស្តែងផ្សេងៗទៀតតាមការកំណត់របស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

## ជំពូកទី៤

## លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់មូលនិធិ និងការទូទាត់រំលងវិភាគទានមូលនិធិជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍

**មាត្រា២៣.-**

បុគ្គលដែលមានសិទ្ធិស្នើសុំមូលនិធិ **ស.អ.** ឬស្នើសុំការទូទាត់រំលងវិភាគទានមូលនិធិ **ស.អ.** ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ មានដូចខាងក្រោម៖

- គ្រឹះស្ថានសាធារណៈដែលផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។
- ប្រតិបត្តិករទូរគមនាគមន៍ដែលបានបំពេញប្រតិបត្តិការដូចមានចែងក្នុងមាត្រា១៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ ដែលបានអនុវត្តកាតព្វកិច្ចស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។
- បុគ្គលដែលមានគុណវុឌ្ឍិឆ្លើយតបទៅនឹងកម្មវត្ថុណាមួយដូចមានចែងក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ។

**មាត្រា២៤.-**

ដើម្បីទទួលបានមូលនិធិ **ស.អ.** ឬការទូទាត់រំលងវិភាគទានមូលនិធិ **ស.អ.** ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ បុគ្គលស្នើសុំត្រូវបញ្ជាក់៖

- បានអនុវត្តកាតព្វកិច្ចបង់វិភាគទាន ដោយប្រតិបត្តិករទូរគមនាគមន៍ចូលមូលនិធិ **ស.អ.** ត្រឹមត្រូវតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិផ្សេងទៀត
- ពុំមានជាប់បំណុលដោយខកខានបង់វិភាគទានចូលមូលនិធិ **ស.អ.**
- មានសក្តានុពលភាពផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងមានឆន្ទៈក្នុងការសម្រេចនូវគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
- ប្រសិនបើបុគ្គលស្នើសុំជាប្រតិបត្តិករទូរគមនាគមន៍៖ ត្រូវអនុវត្តរួមគ្នាជាមួយនឹងគ្រឹះស្ថានសាធារណៈដែលផ្តល់ការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន យ៉ាងហោចណាស់ចំនួនមួយ
- ចំពោះបុគ្គលស្នើសុំមូលនិធិ **ស.អ.** ៖ ត្រូវផ្តល់នូវគម្រោងបច្ចេកទេសនិងហិរញ្ញវត្ថុលម្អិតនិងគោរពតាមលក្ខខណ្ឌនិងនីតិវិធីដែលកំណត់ដោយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- ចំពោះបុគ្គលស្នើសុំទូទាត់រំលងវិភាគទានមូលនិធិ **ស.អ.** ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍៖ ត្រូវភ្ជាប់គម្រោងបច្ចេកទេសនិងហិរញ្ញវត្ថុនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ដែលឆ្លើយតបយ៉ាងជាក់ស្តែងទៅនឹងផែនការអាទិភាពប្រចាំឆ្នាំនៃគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ដែលត្រូវបានធ្វើសវនកម្មរួច។

**មាត្រា២៥.-**

គម្រោងអនុវត្តការកសាងសមត្ថភាព ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ត្រូវបានផ្តល់តាមករណីដូចខាងក្រោម៖

ក- ករណីសំណើសុំគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ តាមរយៈការផ្សព្វផ្សាយជាសាធារណៈ ៖

- លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវប្រកាសរកបុគ្គលអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ តាមរយៈការផ្សព្វផ្សាយជាសាធារណៈ
- **ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចជ្រើសរើសយកវិធីដាក់ឱ្យដេញថ្លៃគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ឬជ្រើសរើសយកបុគ្គលអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត
- បុគ្គលស្នើសុំគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ត្រូវផ្តល់នូវគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុលម្អិត និងគោរពតាមលក្ខខណ្ឌនិងនីតិវិធីដែលកំណត់ដោយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**
- **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវសម្រេចផ្តល់គម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវ-ជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ដល់បុគ្គលដែលបានស្នើសុំគម្រោងនេះ បន្ទាប់ពីបានពិនិត្យនិងវាយតម្លៃលើសំណុំឯកសារតាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន
- សេចក្តីសម្រេចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចត្រូវបានតវ៉ាទៅតុលាការមានសមត្ថកិច្ចដោយបុគ្គលស្នើសុំគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។ សេចក្តីសម្រេចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលស្នើសុំគម្រោងអនុវត្តមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ខ- ករណីស្នើសុំទូទាត់រវាងវិភាគទានមូលនិធិ **ស.អ.** ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍៖

- នីតិវិធីដែលមានចែងក្នុងចំណុច (ក) ខាងលើត្រូវយកមកអនុវត្តដូចគ្នា
- **ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានសិទ្ធិសម្រេចដាក់ឱ្យដេញថ្លៃក្នុងករណីដែលមានសំណើច្រើនលើការទូទាត់រវាងវិភាគទានមូលនិធិ **ស.អ.** ជាមួយនឹងគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ដូចគ្នា។

រាល់គម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ដែលត្រូវបានអនុម័តយល់ព្រមដោយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវផ្សព្វផ្សាយជាសាធារណៈ។

**មាត្រា២៦.-**

ការផ្តល់ថវិកាដល់បុគ្គលអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ត្រូវធ្វើឡើងតាមរយៈការផ្ទេររវាងគណនីធនាគារ និងតាមដំណាក់កាល ស្របតាមការសម្រេចនៃការអនុវត្ត

គម្រោងដោយភ្ជាប់មកជាមួយនូវរបាយការណ៍លម្អិតនៃការសម្រេចគម្រោង។ នីតិវិធីនៃការផ្តល់ថវិកានេះអាចត្រូវបានកំណត់បន្ថែមដោយសេចក្តីសម្រេចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

## ជំពូកទី៥
## ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃ ការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា២៧ .-**

បុគ្គលទទួលបានគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ តាមការស្នើសុំរបស់លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

បុគ្គលទទួលបានគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ត្រូវបង្កភាពងាយស្រួលនិងសហការជាមួយ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ឬលេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ក្នុងការចុះត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងរបស់បុគ្គលទទួលបានគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ និងត្រូវឆ្លើយតបទៅនឹងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងគម្រោង។

ក្នុងករណីដែលគម្រោងណាមួយមិនដំណើរការ ឬដំណើរការពុំស្របតាមផែនការសកម្មភាព លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវធ្វើរបាយការណ៍ជូន **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ព្រមទាំងស្នើសុំចាត់វិធានការបន្ទាន់ដើម្បីផ្អាកឬបញ្ឈប់ការអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍។

**មាត្រា២៨ .-**

លេខាធិការដ្ឋាននៃ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមូលនិធិ **ស.អ.** ដាក់ជូនទៅ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដើម្បីពិនិត្យនិងសម្រេច។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា២៩ .-**

ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ មិនអនុវត្តតាមកាតព្វកិច្ចណាមួយដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចស្នើសុំទៅ **ក.ប.ទ.** ដើម្បីចាត់វិធានការ ជាអាទិ៍ ដូចខាងក្រោម៖

ក- ដឹកនាំកែតម្រូវប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ឱ្យអនុវត្តតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម

ខ- បង្អាកការនាំចេញឬការនាំចូលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

គ- បង្កកគណនីរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍

ឃ- ដាក់កំហិតលើអាជ្ញាបណ្ណ

ង- ព្យួរអាជ្ញាបណ្ណ

ច- ព្យួរបណ្ដោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍

ឆ- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍

ជ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍

ឈ- ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៣០ ..**

ដោយពុំទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត បុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ក្នុងស្ថានភាពមិនសមស្រប ឬ/និងធ្វើឱ្យបាត់បង់ដោយប្រការណាមួយតាមរយៈការលួចកិបកេង ក្លែងបន្លំ ប្រើប្រាស់មូលនិធិ **ស.អ.** ខុសគោលដៅ ឬអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍មិនត្រឹមត្រូវ, **ក្រុមប្រឹក្សាមូលនិធិ ស.អ.** អាចស្នើសុំទៅ **ក.ប.ទ.** ដើម្បីចាត់វិធានការសមស្របដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។

បុគ្គលដែលទទួលបានមូលនិធិ **ស.អ.** ដើម្បីអនុវត្តគម្រោងអនុវត្តការកសាងសមត្ថភាព ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ ដែលប្រើប្រាស់មូលនិធិ **ស.អ.** មិនសមស្រប ឬ/និងធ្វើឱ្យបាត់បង់ដោយប្រការណាមួយ ត្រូវសងមកវិញនូវចំនួនទឹកប្រាក់ដែលទទួលបានពី **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ដោយភ្ជាប់នូវការប្រាក់ដែលកំណត់ដោយច្បាប់គិតចាប់ពីថ្ងៃប្រព្រឹត្តល្មើស។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា៣១ ..**

ប្រតិបត្តិករទូរគមនាគមន៍ត្រូវបង់វិភាគទានសម្រាប់ឆ្នាំ២០១៧ ដោយផ្អែកលើចំណូលដុលប្រចាំឆ្នាំ២០១៦ មក **ក្រុមប្រឹក្សាមូលនិធិ ស.អ.**។

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** ត្រូវកំណត់កាលបរិច្ឆេទនៃការបង់វិភាគទានសម្រាប់ឆ្នាំ២០១៧។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ